Declassified to Public
27 June 2019

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 02 / 2015
ម៉ោង (Time/Heure): 15:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារ E319/11/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង** សម្ងាត់ / Confidential / Confidentiel

ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ជូនចំពោះ៖ ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖ លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឲ្យទទួលយកឯកសារពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អនុលោមតាមវិធាន ៨៧(៣) និងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង - សម្ងាត់**

១. នៅពីថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយពីសហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីពីក្នុងសំណុំរឿង ០០៤ ដែលក្នុងនោះ កំណត់ហេតុចំនួនពីរពាក់ព័ន្ធនឹងសាក្សី 2-TCW-852 កំណត់ហេតុចំនួនមួយពាក់ព័ន្ធនឹងសាក្សី 2-TCW-977 និងកំណត់ហេតុមួយទៀតពាក់ព័ន្ធនឹងសាក្សី 2-TCW-822 (ឯកសារ E319/11 កថាខណ្ឌ ១ ដល់ កថាខណ្ឌ ៤។ សូមមើលផងដែរ ឧបសម្ព័ន្ធសម្ងាត់ដែលបានដាក់ភ្ជាប់ជាមួយនឹងអនុស្សរណៈនេះ)។ កំណត់ហេតុទាំងនេះ ដែលត្រូវបានដាក់បង្ហាញនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ (ឯកសារ E319/11 កថាខណ្ឌ ១ បានយោងទៅឯកសារ E319/8។ *សូមមើលផងដែរ* ឯកសារ E319/10) ត្រូវបានកំណត់អត្តសញ្ញាណ

បន្ថែមទៀតនៅក្នុងតារាងមួយភ្ជាប់មកជាមួយនឹងសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (*សូមមើល* ឧបសម្ព័ន្ធសម្ងាត់ ចៈ ឯកសារ E319/11.1)។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា កំណត់ហេតុទាំងនេះ "ពាក់ព័ន្ធខ្លាំង" ជាមួយនឹងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២/០២ ជាពិសេសចំពោះសហករណ៍ត្រាំកក់ និងទីតាំងឧក្រិដ្ឋកម្មនៃមន្ទីរសន្តិសុខក្រាំង-តាចាន់ (ឯកសារ E319/11 កថាខណ្ឌ ២)។ គ្មានភាគីណាមួយបានឆ្លើយតបទៅនឹងសំណើសុំនេះឡើយ។

២. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងថ្មីទាំងឡាយណាដែលខ្លួនយល់ឃើញថា អាចបញ្ជាក់ការពិត ក្នុងករណីដែលភស្តុតាងទាំងនោះបានបំពេញបទដ្ឋាន*បឋម (prima facie)* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថា-ភាព ដែលជាលក្ខខណ្ឌតម្រូវនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងក៏បានតម្រូវផងដែរថា ភាគីស្នើសុំឱ្យទទួលយកភស្តុតាងថ្មី ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីស្នើសុំត្រូវធ្វើយ៉ាងណាឱ្យអង្គជំនុំជម្រះសាលាដំបូងជឿថា ភស្តុតាងដែលបានស្នើសុំពុំអាចរកបាននៅមុនពេលបើកការជំនុំជម្រះ ឬ មិនអាចរកឃើញនាពេលមុន បើទោះជាបានខិតខំប្រឹងប្រែងរកយ៉ាងសមស្របរួចហើយក៏ដោយ។ អង្គជំនុំ-ជម្រះធ្លាប់បានបញ្ជាក់រួចហើយថា ឯកសារដែលពុំត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីបឋមរបស់ភាគី អនុលោមតាមវិធាន ៨០(៣) នៃវិធានផ្ទៃក្នុង គឺជាភស្តុតាងថ្មី ដែលត្រូវគោរពតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏ប៉ុន្តែ អង្គជំនុំជម្រះអាចទទួលយកឯកសារណាមួយបាន ក្នុងករណីដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យធ្វើដូច្នេះ (ឯកសារ E282/2 បានយោងលើឯកសារ E190 កថាខណ្ឌ ១៩-២១)។

៣. សហព្រះរាជអាជ្ញាសន្និដ្ឋានថា កំណត់ហេតុនៃការស្តាប់ចម្លើយដែលខ្លួនបានស្នើសុំឱ្យទទួលយក ត្រូវបានផ្តល់ជូននៅក្នុងឆ្នាំ ២០១៣ ឬ ឆ្នាំ ២០១៤ ហេតុដូច្នេះ ពុំអាចរកបាននៅមុនពេលបើកការជំនុំជម្រះក្នុងខែ មិថុនា ឆ្នាំ ២០១១ ឡើយ។ សហព្រះរាជអាជ្ញាសន្និដ្ឋានបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិទើបតែបានផ្តល់សិទ្ធិឱ្យខ្លួនដាក់បង្ហាញកំណត់ហេតុទាំងនេះនៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ប៉ុណ្ណោះ (ឯកសារ E319/11 កថាខណ្ឌ ៣)។

 

៤. អង្គជំនុំជម្រះសាលាដំបូងរម្លឹកឡើងវិញថា ទោះបីជាបញ្ជីឯកសារដែលភាគីបានដាក់នៅក្នុងឆ្នាំ ២០១១ មាននៅក្នុងសំណុំរឿង ០០២ ទាំងមូលក៏ដោយ ក៏អង្គជំនុំជម្រះបានសម្រេចជាករណីលើកលែងមួយថា បញ្ជីទាំងឡាយដែលបានដាក់នៅក្នុងឆ្នាំ ២០១៤ គឺជាបញ្ជីកែសម្រួលលើបញ្ជីឆ្នាំ ២០១១ ដែលអាចអនុញ្ញាតឱ្យធ្វើទៅបាន។ ឆ្នាំ ២០១១ គឺជាកាលបរិច្ឆេទកំណត់សម្រាប់ការពិចារណាថាតើភស្តុតាងទាំងនេះអាចរកបាន ឬរកមិនបាន នៅមុនបើកការជំនុំជម្រះសំណុំរឿង ០០២/០២ (*សូមមើល* ឯកសារ E307/1/2 ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤)។ កំណត់ហេតុស្តាប់ចម្លើយសាក្សី 2-TCW-852 និងសាក្សី 2-TCW-822 ត្រូវបានផ្តល់ជូននៅថ្ងៃទី ១១ ថ្ងៃទី ១២ និងថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៤ ដោយឡែកៗពីគ្នា ហេតុដូច្នេះ ពុំអាចរកបាននៅមុនពេលចាប់ផ្តើមសំណុំរឿងនេះឡើយ។ កំណត់ហេតុស្តាប់ចម្លើយសាក្សី 2-TCW-977 ដែលត្រូវបានផ្តល់ជូននៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ក៏ពុំអាចរកបានដូចគ្នាដែរ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សហព្រះរាជអាជ្ញាអន្តរជាតិបានប្រឹងប្រែងយ៉ាងត្រឹមត្រូវក្នុងការស្នើសុំឱ្យទទួលយកកំណត់ហេតុទាំងនេះតាំងពីមុនដំបូងបំផុតដោយបានស្នើសុំដាក់បង្ហាញឯកសារទាំងនេះនៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ ភ្លាមៗក្រោយពេលអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និង វិសាលភាពនៃសំណុំរឿង ០០២/០២ (ឯកសារ E301/9/1)[៧]។ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតទើបតែបានផ្តល់សិទ្ធិឱ្យដាក់បង្ហាញកំណត់ហេតុទាំងនេះនៅក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ នេះនោះ (*សូមមើលផងដែរ* ឯកសារ E319/12.1.1) កំណត់ហេតុស្តាប់ចម្លើយទាំងនេះមិនទាន់ត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចដោះស្រាយនៅក្នុងឯកសារ E307/1/2 នៅឡើយទេ។

៥. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់បន្ថែមទៀតថា កំណត់ហេតុស្តាប់ចម្លើយទាំងនេះត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេតមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហេតុដូច្នេះបានបំពេញបទដ្ឋាន*បឋម* ស្តីពីភាពអាចជឿជាក់បាន និងយថាភាពរួចហើយ។ សាក្សី 2-

[៧] យោងតាមព័ត៌មានដែលអង្គជំនុំជម្រះសាលាដំបូងបានទទួលនៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៤ បង្ហាញថា សហព្រះរាជអាជ្ញាអន្តរជាតិទំនងស្នើសុំបង្ហាញនូវ "គ្រប់កំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់ទាក់ទងនឹងសំណុំរឿង ០០២/០២ ដែលបានមកពីក្នុងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២" (ឯកសារ E319 កថាខណ្ឌ ២)។ *សូមមើលផងដែរ* ឯកសារ E319/8.3 កថាខណ្ឌ ២ និងឯកសារ E319.2 កថាខណ្ឌ ៨។

TCW-852 បានលើកឡើងថា គាត់ "អាចចេញចូលមន្ទីរសន្តិសុខក្រាំងតាចាន់" បាន ហើយ ទាហាន និងអ្នករដ្ឋការខ្លះត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងនានា ដូចជា ក្រាំងតាចាន់ជាដើម (ឯកសារ E319/8.2.2 និងឯកសារ E319/8.2.1)។ សាក្សី 2-TCW-977 បានលើកឡើងថា គាត់បានធ្វើការងារនៅក្នុងមន្ទីរសន្តិសុខមួយដែលស្ថិតនៅជិតវត្តអង្គញដី ដែល "ប្រជាជនថ្មី" ត្រូវបានបញ្ជូនទៅទីនោះ ហើយអ្នកជាប់ឃុំមួយចំនួនត្រូវបានគេធ្វើទារុណកម្ម (ឯកសារ E319/8.2.3)។ សាក្សី 2-TCW-822 បានលើកឡើងថា គាត់បានធ្វើការងារនៅក្នុងកងមួយក្នុងស្រុកត្រាំកក់ ហើយបានពិពណ៌នាអំពីសិទ្ធិអំណាចរបស់បុគ្គលដែលទទួលខុសត្រូវនៅទីនោះ (ឯកសារ E319/8.2.4)។ សាក្សី 2-TCW-852 និងសាក្សី 2-TCW-822 គ្រោងនឹងមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះអាចលាតត្រដាងការពិត ហើយពាក់ព័ន្ធ *ជាបឋម* នឹងសំណុំរឿង ០០២/០២។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ភាគីផ្សេងៗទៀតពុំបានជំទាស់ទៅនឹងការទទួលយកចម្លើយទាំងនេះនោះទេ។

៦. ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា លក្ខខណ្ឌតម្រូវនៅក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ត្រូវបានបំពេញរួចហើយ ហើយអង្គជំនុំជម្រះសាលាដំបូងឯកភាពតាមសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលសុំឱ្យទទួលយកនូវកំណត់ហេតុខាងលើមកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីថា ការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយទាំងនេះត្រូវគោរពតាមលក្ខខណ្ឌនីតិវិធី ដូចដែលមានចែងនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ឯកសារលេខ E319/7។

៧. អនុស្សរណៈនេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E319/11។